**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្តកំពង់ធំ

**រដ្ឋបាលខេត្តកំពង់ធំ**
លេខ៖ ៤២៤៦/២០ សសរ

ថ្ងៃ...ច័ន្ទ ៥កើត...ខែ...អស្សុជ...ឆ្នាំជូតទោស័ក ព.ស២៥៦៤
កំពង់ធំ,ថ្ងៃទី...២២......ខែ...កញ្ញា...ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
## ស្តីពីការរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ ២០២១

**យោង÷** លិខិតលេខ០៨៨ ស.ជ.ណ/គ.ជ.អ.ប ចុះថ្ងៃទី០៧ខែកញ្ញា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

រដ្ឋបាលខេត្តកំពង់ធំនឹងរៀបចំបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០២១ សម្រាប់ដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០២១។ អ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការមានសិទ្ធិដាក់សំណើដេញថ្លៃគម្រោងមូលនិធិឃុំ សង្កាត់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

អ្នកទទួលការត្រូវបានបែងចែកជា០៣ប្រភេទ៖

- ប្រភេទទី១៖ អ្នកទទួលការសំណង់ទូទៅ (សំណង់អាគារ និងការងារបេតុង...។ល។)
- ប្រភេទទី២៖ អ្នកទទួលការការងារដី(ប្រឡាយទំនប់ ទ្វារទឹកខ្នាតតូច ផ្លូវដីស ផ្លូវក្រួសក្រហម លូមូល...។ល។)
- ប្រភេទទី៣៖ អ្នកទទួលការឯកទេស(អ្នកទទួលការដែលមានឧបករណ៍ និងជំនាញបច្ចេកទេស សម្រាប់ការងារពិសេស ឧទាហរណ៍ អណ្តូងស្នប់...។ល។)

អ្នកទទួលការត្រូវមានបុគ្គលិកបច្ចេកទេស និងសម្ភារបរិក្ខារគ្រប់គ្រាន់ ដូចមានបរិយាយនៅក្នុងពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ ដើម្បីអនុវត្តការងារទៅតាមប្រភេទដែលបានស្នើសុំ ហើយត្រូវមានបទពិសោធន៍ អនុវត្តគម្រោងយ៉ាងតិច០២ទាក់ទងនឹងប្រភេទនីមួយៗដែលបានស្នើសុំក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ។ គណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងចុះពិនិត្យដល់ទីតាំងក្រុមហ៊ុនរបស់អ្នកទទួលការ និងវាយតម្លៃសមត្ថភាពបច្ចេកទេសដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចមានបរិយាយនៅក្នុងពាក្យសុំចុះបញ្ជី ព្រមទាំងពិនិត្យមើលគុណភាពការងារ ភាពស្មោះត្រង់ ការអនុវត្តការងារទាន់ពេលវេលា និងកិច្ចសហប្រតិបត្តិការរបស់អ្នកទទួលការជាមួយម្ចាស់គម្រោង ដោយផ្អែកលើកំណត់ត្រាកន្លង មក។ លទ្ធផលនៃការវាយតម្លៃនេះ គណៈកម្មការបុរេលក្ខណៈសម្បត្តិនឹងដាក់ជូន អភិបាលខេត្តដើម្បីពិនិត្យ និងសម្រេច។

អ្នកទទួលការទាំងឡាយណាដែលត្រូវបានរកឃើញថា មានការពាក់ព័ន្ធនឹងការឃុបឃិត ការក្លែងបន្លំនឹងអំពើពុករលួយ ហើយចាប់ពីពេលដែលត្រូវបានដកសិទ្ធិជាផ្លូវការ អ្នកទទួលការនោះ នឹងមិនត្រូវបានពិចារណាក្នុងការដាក់បញ្ចូលឈ្មោះអ្នកទទួលការឡើយ។

អាស្រ័យហេតុនេះ បើអ្នកទទួលការមានបំណងចុះឈ្មោះក្នុងបញ្ជីអ្នកទទួលការ សូមរួសរាន់មកដាក់ពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការនៅទីចាត់ការផែនការ និងវិនិយោគខេត្តចាប់ពីថ្ងៃជូនដំណឹងនេះ រហូតដល់ថ្ងៃទី**១៦ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ៥៖៣០នាទីរសៀល**។ ចំពោះអ្នកទទួលការដែលមានឈ្មោះក្នុងបញ្ជីឆ្នាំកន្លងមក ក៏ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកទទួលការ ជាថ្មីឡើងវិញដែរ។ អ្នកទទួលការអាចមកយកពាក្យសុំចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការ នៅទីចាត់ការផែនការ និងវិនិយោគខេត្តដោយឥតបង់ថ្លៃតាមអាសយដ្ឋាន ភូមិទី៧ សង្កាត់កំពង់ធំ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឬអាចទំនាក់ទំនងតាមទូរស័ព្ទលេខ ០៧៨ ៧១ ៤០ ០៥។

**អភិបាល**

**ចម្លងជូន÷**
- ក្រសួងមហាផ្ទៃ
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីជូនជ្រាប"
- ឯកសារ កាលប្បវត្តិ